**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០១១៧ ព.ណ.ក.កម.ប្រក

# ប្រកាស
# ស្តីពី
# នីតិវិធីបញ្ជាក់ និងការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ខែ មីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញសារាចរណែនាំលេខ០៧ សរណន ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៥ ស្តីពីការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក របស់រាជរដ្ឋាភិបាល
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

### ប្រការ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់នីតិវិធីគ្រប់គ្រងការបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក និងការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កើនប្រសិទ្ធភាពអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា លុបបំបាត់ការប្រកួតប្រជែងមិនស្មោះត្រង់ ផ្តល់ការការពារ និងផលប្រយោជន៍របស់ម្ចាស់សិទ្ធិ និងសាធារណៈ ដោយទប់ស្កាត់ការនាំចូល និងចែកចាយទំនិញក្លែងក្លាយ ការលក់បង្ខូចថ្លៃ បំពេញតាមស្តង់ដារជាតិ អន្តរជាតិ ដើម្បីលើកកម្ពស់ពាណិជ្ជកម្ម និងវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា។


ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

**ប្រការ២.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តលើការបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក និងការកត់ត្រាលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ចំពោះទំនិញនាំចូលដែលសុទ្ធ និងថ្មី ដែលបានចុះបញ្ជីម៉ាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបានកំណត់ក្នុងសារាចរណែនាំលេខ ០៧ សរណន ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការទទួលស្គាល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.- និយមន័យ**

**វាក្យសព្ទដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ដូចខាងក្រោម៖**

១. **ការប្រគល់សិទ្ធិផ្ដាច់មុខ** គឺជាការព្រមព្រៀងដោយស្ម័គ្រចិត្តរវាងអ្នកប្រគល់សិទ្ធិ និងអ្នកទទួលសិទ្ធិ ក្នុងការអនុញ្ញាតឱ្យប្រើប្រាស់ម៉ាកផ្ដាច់មុខសម្រាប់ការនាំចូល និងចែកចាយទំនិញក្នុងព្រះរាជាណាចក្រកម្ពុជា។

២. **ទំនិញក្រោមសិទ្ធិផ្ដាច់មុខ** សំដៅដល់ទំនិញដែលទទួលបានលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក ឬទទួលបានលិខិតកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ពីក្រសួងពាណិជ្ជកម្ម ហើយដែលអាចអនុវត្តសិទ្ធិដូចមានចែងក្នុងប្រកាសនេះ។

៣. **លិខិតប្រគល់សិទ្ធិផ្ដាច់មុខ** សំដៅដល់លិខិតជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយអ្នកប្រគល់សិទ្ធិជូនទៅអ្នកទទួលសិទ្ធិ ដែលមានអាសយដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យប្រើប្រាស់ម៉ាកផ្ដាច់មុខសម្រាប់ការនាំចូល និងចែកចាយទំនិញក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមានការបញ្ជាក់អំពីម៉ាក ជំពូក យថាប្រភេទ និង/ឬ ម៉ូឌែលនៃទំនិញ។

៤. **លិខិតបញ្ជាក់ការអនុញ្ញាតឱ្យប្រគល់សិទ្ធិបន្ត** សំដៅដល់លិខិតជាលាយលក្ខណ៍អក្សរ ដែលធ្វើឡើងដោយអ្នកប្រគល់សិទ្ធិ ជូនអ្នកប្រគល់សិទ្ធិបន្ត ដែលមានអាសយដ្ឋានក្នុង ឬក្រៅ ព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យបន្តការផ្ដល់សិទ្ធិផ្ដាច់មុខជូនអ្នកទទួលសិទ្ធិ ដែលមានអាសយដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងការប្រើប្រាស់ម៉ាកផ្ដាច់មុខសម្រាប់ការនាំចូល និងចែកចាយទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមានការបញ្ជាក់អំពីម៉ាក ជំពូក យថាប្រភេទ និង/ឬ ម៉ូឌែលនៃទំនិញ។

៥. **លិខិតប្រគល់សិទ្ធិផ្ដាច់មុខបន្ត** សំដៅដល់លិខិតជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយអ្នកប្រគល់សិទ្ធិបន្តដែលជានីតិបុគ្គលដែលមានអាសយដ្ឋាននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលលិខិតបញ្ជាក់ការអនុញ្ញាតឱ្យប្រគល់សិទ្ធិបន្តពីអ្នកប្រគល់សិទ្ធិជាមុនសិន បន្ទាប់មក អ្នកប្រគល់សិទ្ធិបន្តចេញលិខិតប្រគល់សិទ្ធិផ្ដាច់មុខបន្ត ជូនអ្នកទទួលសិទ្ធិដែលមានអាសយដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ក្នុងការប្រើប្រាស់ម៉ាកផ្ដាច់មុខសម្រាប់ការនាំចូល និងចែកចាយទំនិញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមានបញ្ជាក់អំពីម៉ាក ជំពូក យថាប្រភេទ និង/ឬ ម៉ូឌែលនៃទំនិញ។

៦. **លិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក** សំដៅដល់លិខិតរបស់ក្រសួងពាណិជ្ជកម្ម ដែលបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក សម្រាប់ការនាំចូល និងចែកចាយទំនិញក្នុងព្រះរាជាណាចក្រកម្ពុជា តាមការស្នើសុំរបស់ម្ចាស់ម៉ាកក្នុងស្រុកដែលបានចុះបញ្ជីម៉ាក និងមានអាសយដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៧. **លិខិតកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក** សំដៅដល់លិខិតរបស់ក្រសួងពាណិជ្ជកម្មដែលបានកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាកសម្រាប់ការនាំចូល និងចែកចាយទំនិញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ពីអ្នកប្រគល់សិទ្ធិដែលបានចុះបញ្ជីម៉ាកនៅព្រះរាជាណាចក្រកម្ពុជា ជូនអ្នកទទួលសិទ្ធិជានីតិបុគ្គលដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៨. **អ្នកប្រគល់សិទ្ធិ** សំដៅដល់ម្ចាស់ម៉ាកដែលមានអាសយដ្ឋាននៅក្រៅព្រះរាជាណាចក្រកម្ពុជាដែលបានចុះបញ្ជីម៉ាកនៅព្រះរាជាណាចក្រកម្ពុជា ហើយប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកជូនអ្នកទទួលសិទ្ធិ ដែលមានអាសយដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកនៅក្រសួងពាណិជ្ជកម្ម។

៩. **ម្ចាស់ម៉ាកក្នុងស្រុក** សំដៅដល់នីតិបុគ្គល ដែលមានអាសយដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបានចុះបញ្ជីម៉ាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយស្នើសុំក្រសួងពាណិជ្ជកម្មធ្វើការបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាកក្នុងការនាំចូល និងចែកចាយទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

១០. **អ្នកទទួលសិទ្ធិ** រួមមាន អ្នកទទួលសិទ្ធិផ្ទាល់ និងអ្នកទទួលសិទ្ធិបន្ត។ អ្នកទទួលសិទ្ធិផ្ទាល់ ដែលមានអាសយដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលសិទ្ធិផ្តាច់មុខពីអ្នកប្រគល់សិទ្ធិ ហើយដែលបានដាក់ពាក្យស្នើសុំកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខ ក្នុងការប្រើប្រាស់ម៉ាកនៅក្រសួងពាណិជ្ជកម្ម។ អ្នកទទួលសិទ្ធិបន្ត ដែលមានអាសយដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា បានទទួលសិទ្ធិពីអ្នកប្រគល់សិទ្ធិបន្ត ហើយដែលបានដាក់ពាក្យស្នើសុំកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខ ក្នុងការប្រើប្រាស់ម៉ាកនៅក្រសួងពាណិជ្ជកម្ម។

## ប្រការ៤.- ទំនិញដែលលើកលែងសិទ្ធិផ្តាច់មុខ

ទំនិញដែលមិនអនុញ្ញាតឱ្យធ្វើការបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកក្នុងការនាំចូល និងចែកចាយទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានដូចខាងក្រោម៖

១. ទំនិញដែលបានប្រើប្រាស់រួចគ្រប់ប្រភេទ។

២. ផលិតផលឱសថសម្រាប់មនុស្ស និងសត្វ។

៣. ជី និងថ្នាំកសិកម្ម។

៤. មុខទំនិញហាមឃាត់ ដូចមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ប្រការ៥.- ទំនិញជាប់កម្រិតកំណត់

ទំនិញជាប់កម្រិតកំណត់ដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន លើកលែងទំនិញដែលមានចែងក្នុងចំណុច២ និងចំណុច៣ នៃប្រការ៤ខាងលើ អាចអនុញ្ញាតឱ្យធ្វើការបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬធ្វើការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខ ក្នុងការប្រើប្រាស់ម៉ាកនៅក្រសួងពាណិជ្ជកម្មបាន លុះត្រាតែមានលិខិតអនុញ្ញាតឱ្យនាំចូលពីក្រសួងស្ថាប័នមានសមត្ថកិច្ច ឬរាជរដ្ឋាភិបាលជាមុន។

## ប្រការ៦.- ការកម្រិតសិទ្ធិរបស់ម្ចាស់ម៉ាក និងអ្នកទទួលសិទ្ធិ

១. បន្ទាប់ពីក្រសួងពាណិជ្ជកម្មចេញលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិ មិនអាចហាមឃាត់ក្នុងការនាំចូលទំនិញ តាមលក្ខខណ្ឌដូចខាងក្រោម៖

ក. ទំនិញក្រោមសិទ្ធិផ្តាច់មុខដែលនាំចូលយកមកប្រើប្រាស់ដោយស្ថាប័ន ព្រះបរមរាជវាំង ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល។

ខ. ទំនិញក្រោមសិទ្ធិផ្តាច់មុខនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅមិនធ្វើពាណិជ្ជកម្ម និងសម្រាប់ប្រើប្រាស់ជាប្រយោជន៍ដល់សង្គម មនុស្សធម៌ ផ្ទាល់ខ្លួន បេសកកម្មការទូត សហគមន៍ សមាគម អង្គការជាតិ និងអង្គការអន្តរជាតិ ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ការផ្គុំដំឡើងនិងកែច្នៃបន្ថែម ការពិសោធន៍និងស្រាវជ្រាវលក្ខណៈវិទ្យាសាស្ត្រ ទំនិញគំរូសម្រាប់តាំងបង្ហាញ ការអភិវឌ្ឍកសិកម្ម កិច្ចសន្យាផលិតកម្មកសិកម្ម គម្រោងវិនិយោគឯកជន វិនិយោគសាធារណៈ និងទំនិញប្រើប្រាស់រួចគ្រប់ប្រភេទ។

គ. ចំពោះទំនិញក្រោមសិទ្ធិផ្តាច់មុខ ដែលនាំចូលដោយរូបវន្តបុគ្គលក្នុងអីវ៉ាន់ផ្ទាល់ខ្លួនដែលគ្មានលក្ខណៈពាណិជ្ជកម្ម ត្រូវលើកលែងការអនុវត្តសិទ្ធិផ្តាច់មុខក្នុងប្រកាសនេះ។

ឃ. ទំនិញនាំចូល ដើម្បីនាំចេញគ្រប់ប្រភេទ។

## ប្រការ៧._ សិទ្ធិផ្តាច់មុខដែលទទួលបាន

១. សិទ្ធិនាំចូល និងចែកចាយទំនិញផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានទទួលស្គាល់តាមរយៈការបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកនៅក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

២. ម្ចាស់ម៉ាកក្នុងស្រុកដែលទទួលបានការបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬអ្នកទទួលសិទ្ធិពីការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក មានសិទ្ធិប្តឹងទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ចំពោះបុគ្គលណាដែលបាននាំចូល និងចែកចាយទំនិញក្រោមសិទ្ធិផ្តាច់មុខស្របគ្នាដោយរំលោភបំពាននូវសិទ្ធិរបស់ខ្លួន ដើម្បីរកដំណោះស្រាយដូចមានចែងក្នុងប្រការ១៦ នៃប្រកាសនេះ។

៣. សិទ្ធិនាំចូល និងចែកចាយទំនិញក្រោមលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវផុតរលត់វិញ នៅពេលដែលទំនិញក្រោមសិទ្ធិផ្តាច់មុខនីមួយៗ ត្រូវបានលក់លើកដំបូងនៅក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ៨._ បទប្បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិផ្តាច់មុខតាមរយៈការចុះបញ្ជីម៉ាក

**១. ការទទួលបានសិទ្ធិផ្តាច់មុខតាមរយៈការចុះបញ្ជីម៉ាក**

ដើម្បីទទួលបានសិទ្ធិផ្តាច់មុខលើម៉ាក អ្នកស្នើសុំត្រូវចុះបញ្ជីម៉ាកនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមមាត្រា៣ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។ សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាក រួមមាន ការផលិត ការផ្សព្វផ្សាយ ការលក់ ការនាំចេញ ការនាំចូលជាដើម ដូចមានកំណត់ក្នុងមាត្រា១១ មាត្រា២៤ និងមាត្រា៦៦ នៃច្បាប់ខាងលើ។ សិទ្ធិផ្តាច់មុខដែលទទួលបានពីការចុះបញ្ជីម៉ាក អាចផ្ទេរម្ចាស់កម្មសិទ្ធិម៉ាកទៅឱ្យភាគីណាមួយបាន លុះត្រាតែមានការយល់ព្រមពីម្ចាស់ម៉ាក និងបានធ្វើការកត់ត្រា នៅក្រសួងពាណិជ្ជកម្ម។

**២. គោលការណ៍ផុតរលត់សិទ្ធិ**

ក. សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាក មិនត្រូវបានរាប់បញ្ចូលការដាក់លក់ទំនិញនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់ម៉ាក ឬដោយបុគ្គលដែលមានការយល់ព្រមពីម្ចាស់ម៉ាកនោះឡើយ ដូចបានកំណត់ក្នុងមាត្រា១១(គ) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលកម្ពុជាបានកំណត់យកគោលការណ៍ផុតរលត់សិទ្ធិកម្រិតជាតិ។

ខ. ផ្អែកតាមគោលការណ៍ផុតរលត់សិទ្ធិកម្រិតជាតិ ម្ចាស់ម៉ាក ដែលបានចុះបញ្ជី ឬអ្នកទទួលសិទ្ធិពីលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក មានសិទ្ធិដាក់ពាក្យបណ្តឹងទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរមានសមត្ថកិច្ច ដើម្បីហាមឃាត់ការនាំចូលស្របគ្នានូវទំនិញរំលោភបំពានសិទ្ធិផ្តាច់មុខ។

## ប្រការ៩._ លក្ខខណ្ឌ និងឯកសារតម្រូវ

បុគ្គលដែលស្នើសុំបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញតាមលក្ខខណ្ឌ និងផ្តល់ឯកសារតម្រូវ ដូចខាងក្រោម៖

**១. លក្ខខណ្ឌ**

ក. ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិដែលស្នើសុំបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវតែជានីតិបុគ្គល។

ខ. លិខិតប្រគល់សិទ្ធិផ្ដាច់មុខត្រូវធ្វើឡើងតាមការព្រមព្រៀងដោយស្ម័គ្រចិត្ត ជាលាយលក្ខណ៍អក្សរ រវាងអ្នកប្រគល់សិទ្ធិជាមួយអ្នកទទួលសិទ្ធិ ហើយត្រូវចុះហត្ថលេខាដោយអ្នកប្រគល់សិទ្ធិ ឬតំណាង និងត្រូវមានបញ្ជាក់ពីភាពត្រឹមត្រូវនៃសមត្ថកិច្ចរបស់អ្នកចុះហត្ថលេខា ដោយសាការី ឬអង្គភាពដែលមានសមត្ថកិច្ចនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក្រសួងយុត្តិធម៌។

គ. ក្នុងករណីដែលអ្នកប្រគល់សិទ្ធិអនុញ្ញាតឱ្យអ្នកប្រគល់សិទ្ធិបន្ត ប្រគល់សិទ្ធិជូនអ្នកទទួលសិទ្ធិណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមាន៖

១. លិខិតប្រគល់សិទ្ធិផ្ដាច់មុខដែលមានបញ្ជាក់ពីសុពលភាពពីអ្នកប្រគល់សិទ្ធិ ជូនអ្នកប្រគល់សិទ្ធិបន្តដែលមានអាសយដ្ឋាននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ដោយមានបញ្ជាក់ថាអ្នកប្រគល់សិទ្ធិបន្តនេះ អាចប្រគល់សិទ្ធិបន្តជូនអ្នកទទួលសិទ្ធិដែលមានអាសយដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ហើយត្រូវចុះហត្ថលេខាដោយអ្នកប្រគល់សិទ្ធិបន្ត ឬតំណាង និងត្រូវមានការបញ្ជាក់ពីភាពត្រឹមត្រូវនៃសមត្ថកិច្ចរបស់អ្នកចុះហត្ថលេខា ដោយសាការី ឬអង្គភាពដែលមានសមត្ថកិច្ចនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក្រសួងយុត្តិធម៌។

២. អ្នកប្រគល់សិទ្ធិបន្ត ត្រូវចេញលិខិតប្រគល់សិទ្ធិផ្ដាច់មុខបន្ត ជូនអ្នកទទួលសិទ្ធិដែលមានអាសយដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាហើយលិខិតនេះត្រូវមានបញ្ជាក់សុពលភាព។

ឃ. អ្នកទទួលសិទ្ធិ អាចដាក់ពាក្យស្នើសុំការកត់ត្រាលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល ៦ (ប្រាំមួយ) ខែយ៉ាងយូរ គិតចាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខានៅលើលិខិតប្រគល់សិទ្ធិផ្ដាច់មុខ។ ក្នុងករណីដែលលិខិតប្រគល់សិទ្ធិផ្ដាច់មុខមានកំណត់ពីកាលបរិច្ឆេទចូលជាធរមាន ត្រូវជ្រើសរើសកាលបរិច្ឆេទចូលជាធរមាននៃលិខិតប្រគល់សិទ្ធិផ្ដាច់មុខ។

ង. ការដាក់ពាក្យស្នើសុំបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក ឬកត់ត្រាលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវបង់កម្រៃទៅតាមការកំណត់នៅក្នុងប្រកាសអន្តរក្រសួងស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ហើយកម្រៃដែលបានបង់រួចមិនអាចដកយកមកវិញ ឬផ្ទេរបានឡើយ។

ច. ការកត់ត្រាលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក អាចធ្វើទៅបានលុះត្រាតែអ្នកដាក់ពាក្យស្នើសុំបានបំពេញតាមលក្ខខណ្ឌតម្រូវនានានៃប្រកាសនេះ។ ក្រសួងពាណិជ្ជកម្មត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យស្នើសុំ ក្នុងករណីដែលមិនអាចធ្វើការកត់ត្រាបាន ឬតម្រូវឱ្យបំពេញឯកសារបន្ថែម។

ឆ. ទំនិញតែមួយ ដែលទទួលបានការកត់ត្រាលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក នៅក្រសួងពាណិជ្ជកម្មរួចហើយ មិនអាចអនុញ្ញាតឱ្យធ្វើការកត់ត្រាលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាកជូនបុគ្គលផ្សេងទៀតបានឡើយ លើកលែងតែការប្រគល់សិទ្ធិផ្ដាច់មុខនោះ ត្រូវបានដកហូត ឬធ្វើមោឃភាព ឬផុតសុពលភាព។

ជ. ការកត់ត្រាលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក លើទំនិញក្នុងជំពូកតែមួយ ដែលមានម៉ាកដូចគ្នា ប៉ុន្តែមានយថាប្រភេទ និងម៉ូឌែលនៃទំនិញខុសគ្នា អាចអនុញ្ញាតឱ្យធ្វើការកត់ត្រាលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាកបាន លុះត្រាតែលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាកពីអ្នកប្រគល់សិទ្ធិមានបញ្ជាក់អំពីយថាប្រភេទនិងម៉ូឌែលនៃទំនិញនីមួយៗនៃម៉ាក។

ឈ. លិខិតប្រគល់សិទ្ធិផ្ដាច់មុខ មិនអាចអនុវត្តសិទ្ធិក្រោមប្រកាសនេះបានទេ ប្រសិនបើលិខិតប្រគល់សិទ្ធិផ្ដាច់មុខនេះ មិនបានយកមកធ្វើការកត់ត្រាលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាកនៅក្រសួងពាណិជ្ជកម្ម។

**២. ឯកសារតម្រូវ**

ក. ពាក្យស្នើសុំបញ្ជាក់អំពីសិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ត្រូវចុះហត្ថលេខាដោយម្ចាស់ម៉ាកក្នុងស្រុក ឬតំណាង ដែលមានសិទ្ធិចុះហត្ថលេខាក្នុងនាមនីតិបុគ្គល និងមានបោះត្រារបស់នីតិបុគ្គល។ ពាក្យស្នើសុំសម្រាប់ការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវចុះហត្ថលេខា ដោយអ្នកទទួលសិទ្ធិ ឬតំណាង ដែលមានសិទ្ធិចុះហត្ថលេខាក្នុងនាមនីតិបុគ្គល និង/ឬមានបោះត្រារបស់នីតិបុគ្គល។

ខ. លិខិតប្រគល់សិទ្ធិផ្តាច់មុខ និង/ឬលិខិតបញ្ជាក់ការអនុញ្ញាតឱ្យប្រគល់សិទ្ធិបន្ត និង/ឬលិខិតប្រគល់សិទ្ធិផ្តាច់មុខបន្ត ត្រូវមានបញ្ជាក់កាលបរិច្ឆេទសុពលភាព និងព័ត៌មាន ដូចខាងក្រោម៖

១. ឈ្មោះរបស់អ្នកប្រគល់សិទ្ធិ ដែលជាម្ចាស់ម៉ាក បានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងអាសយដ្ឋាន ដូចក្នុងវិញ្ញាបនបត្រចុះបញ្ជីម៉ាក និងឈ្មោះរបស់អ្នកទទួលសិទ្ធិ និងអាសយដ្ឋាន ចំពោះលិខិតប្រគល់សិទ្ធិផ្តាច់មុខ។

២. ឈ្មោះរបស់អ្នកប្រគល់សិទ្ធិ ដែលជាម្ចាស់ម៉ាក បានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងឈ្មោះរបស់អ្នកប្រគល់សិទ្ធិបន្ត ដែលមានអាសយដ្ឋាននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ចំពោះលិខិតបញ្ជាក់ការអនុញ្ញាតឱ្យប្រគល់សិទ្ធិបន្ត។

៣. ឈ្មោះរបស់អ្នកប្រគល់សិទ្ធិបន្ត ដែលមានអាសយដ្ឋានក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា និងអ្នកទទួលសិទ្ធិដែលជានីតិបុគ្គល ដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម និងមានបញ្ជាក់អាសយដ្ឋាន ចំពោះលិខិតប្រគល់សិទ្ធិផ្តាច់មុខបន្ត។

៤. ម៉ាក លេខចុះបញ្ជី ជំពូក និងយថាប្រភេទ ឬម៉ូឌែលនៃទំនិញ។ ចំពោះទោចក្រយានយន្ត ត្រីចក្រយានយន្ត រថយន្ត និងយានយន្តដទៃទៀត ត្រូវមានបញ្ជាក់ពីម៉ាកនៃម៉ូឌែលនីមួយៗ យថាប្រភេទ ឬទំហំស៊ីឡាំងម៉ាស៊ីន និងប្រទេសផលិតឱ្យបានច្បាស់លាស់។

៥. ត្រូវបញ្ជាក់ថាអ្នកទទួលសិទ្ធិ មានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកក្នុងការនាំចូល និងចែកចាយទំនិញ ឬអ្នកប្រគល់សិទ្ធិបន្ត មានសិទ្ធិអនុញ្ញាតបន្តផ្តល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកទៅឱ្យអ្នកទទួលសិទ្ធិក្នុងការនាំចូល និងចែកចាយទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៦. សុពលភាពនៃលិខិតប្រគល់សិទ្ធិផ្តាច់មុខ ឬលិខិតប្រគល់សិទ្ធិផ្តាច់មុខបន្ត ត្រូវមានរយៈពេលអតិបរមា ១០(ដប់) ឆ្នាំ។

៧. ឈ្មោះ និងហត្ថលេខារបស់អ្នកប្រគល់សិទ្ធិ និង/ឬអ្នកប្រគល់សិទ្ធិបន្ត ឬតំណាងដែលមានសិទ្ធិចុះហត្ថលេខា ព្រមទាំងបញ្ជាក់កាលបរិច្ឆេទនៃការចុះហត្ថលេខា។

**គ.ឯកសារភ្ជាប់**

១. លិខិតប្រគល់សិទ្ធិផ្តាច់មុខ និង/ឬលិខិតបញ្ជាក់ការអនុញ្ញាតឱ្យប្រគល់សិទ្ធិបន្ត និង/ឬលិខិតប្រគល់សិទ្ធិផ្តាច់មុខបន្ត ច្បាប់ដើម ឬថតចម្លង ចំនួន ០១(មួយ)ច្បាប់។ ក្នុងករណីការប្រគល់លិខិតខាងលើជាឯកសារថតចម្លង អ្នកដាក់ពាក្យត្រូវប្រគល់លិខិតខាងលើ ច្បាប់ដើមក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យ។

២. លិខិតអនុញ្ញាតឱ្យនាំចូលពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬពីរាជរដ្ឋាភិបាល ចំពោះមុខទំនិញជាប់កម្រិតកំណត់ដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន។

៣. វិញ្ញាបនបត្រចុះបញ្ជីម៉ាក ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី ថតចម្លងចំនួន ០១(មួយ)ច្បាប់។

៤. លក្ខន្តិកៈក្រុមហ៊ុន សម្រង់ព័ត៌មាន និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ថតចម្លងចំនួន ០១(មួយ) ច្បាប់។

៥. ប័ណ្ណពន្ធប៉ាតង់ និងវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម) របស់នីតិបុគ្គល ថតចម្លង ចំនួន ០១(មួយ) ច្បាប់។

៦. វិក្កយបត្របង់កម្រៃសេវាសាធារណៈ។

## ប្រការ១០.- ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក

១. ម្ចាស់ម៉ាកក្នុងស្រុកដែលបានចុះបញ្ជីម៉ាកនៅកម្ពុជា អាចស្នើសុំមកក្រសួងពាណិជ្ជកម្ម ក្នុងការធ្វើការបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ដើម្បីជួយសម្រួលដល់ការនាំចូល និងចែកចាយទំនិញផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា។

២. ការស្នើសុំលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ម្ចាស់ម៉ាកក្នុងស្រុកត្រូវបំពេញតាមលក្ខខណ្ឌ និងភ្ជាប់នូវឯកសារដូចមានកំណត់ក្នុងប្រការ៤ ប្រការ៥ និងប្រការ៩(១)(ង) ប្រការ៩(២)(ក) និង(គ) ដោយលើកលែងចំណុច(២)(គ)(១) នៃប្រការ៩។

## ប្រការ១១.- សុពលភាព កាតព្វកិច្ច និងសិទ្ធិ

### ១. រយៈពេលនៃការអនុវត្តសិទ្ធិ

ក. លិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា មានសុពលភាពសម្រាប់ការអនុវត្តសិទ្ធិរយៈពេល ២(ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទសុពលភាព ដែលបានកំណត់ក្នុងលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាករបស់ក្រសួងពាណិជ្ជកម្ម។

ខ. ក្នុងករណីដែលសុពលភាពរបស់លិខិតប្រគល់សិទ្ធិផ្តាច់មុខ ឬលិខិតប្រគល់សិទ្ធិផ្តាច់មុខបន្ត ឬសុពលភាពនៃវិញ្ញាបនបត្រចុះបញ្ជីម៉ាកមានរយៈពេលតិចជាង ២ (ពីរ) ឆ្នាំ សុពលភាពនៃលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវយកតាមសុពលភាពណា ដែលមានរយៈពេលតិចជាងនៃលិខិតប្រគល់សិទ្ធិផ្តាច់មុខ ឬលិខិតប្រគល់សិទ្ធិផ្តាច់មុខបន្ត ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក។

### ២. កាតព្វកិច្ច

ក. បន្ទាប់ពីក្រសួងពាណិជ្ជកម្ម បានចេញលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានាឱ្យបានទូលំទូលាយ។ ក្នុងករណីចាំបាច់ ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ អាចបញ្ជូនលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកជាឯកសារថតចម្លងឱ្យអ្នកនាំចូលដោយផ្ទាល់ ដើម្បីជូនជ្រាបជាព័ត៌មាន។

ខ. នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវផ្សព្វផ្សាយលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ក្នុងគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម និង/ឬក្នុងគេហទំព័ររបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា និងចម្លងជូនអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គ. អ្នកនាំចូលដទៃទៀតក្រៅពីម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ដែលនាំចូលទំនិញក្រោមលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខថ្មីពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខថ្មីក្នុងការប្រើប្រាស់ម៉ាកដែលចេញដោយក្រសួងពាណិជ្ជកម្ម ត្រូវបញ្ឈប់ការនាំចូលបន្ទាប់ពី ៩០(កៅសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមនៃសុពលភាពដែលបានកំណត់ក្នុងលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខថ្មីពីការចុះបញ្ជីម៉ាក ឬលិខិត

កត់ត្រាប្រគល់សិទ្ធិផ្តាច់មុខថ្មីក្នុងការប្រើប្រាស់ម៉ាកដោយក្រសួងពាណិជ្ជកម្ម។ អ្នកនាំចូលដទៃទៀតដែលមានបំណងនាំចូលទំនិញក្រោមសិទ្ធិផ្តាច់មុខ ត្រូវធ្វើការចុះបញ្ជីការប្រតិវេទន៍គយឱ្យបានឆាប់បំផុត ហើយត្រូវជានាថា ការនាំចូលត្រូវបញ្ចប់ក្នុងកំឡុងពេល ៩០(កៅសិប)ថ្ងៃខាងលើ។ ការបញ្ឈប់ការនាំចូលនេះ មិនអនុវត្តចំពោះទំនិញដែលបានដាក់ចូលកណ្តាគារគយមានដែនកំណត់ មុនកាលបរិច្ឆេទនៃលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខថ្មីពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខថ្មីក្នុងការប្រើប្រាស់ម៉ាកឡើយ។

**៣. សិទ្ធិរបស់ម្ចាស់ម៉ាកក្នុងស្រុក និងអ្នកទទួលសិទ្ធិ**

ក. ចំពោះសិទ្ធិនៃការបញ្ជាក់សិទ្ធិផ្តាច់មុខថ្មីពីការចុះបញ្ជីម៉ាក និងការកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខថ្មីក្នុងការប្រើប្រាស់ម៉ាក ៖

យោងប្រការ១១(២)(គ) ក្រោយរយៈពេល ៩០(កៅសិប) ថ្ងៃ បន្ទាប់ពីក្រសួងពាណិជ្ជកម្មចេញលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខថ្មីពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខថ្មីក្នុងការប្រើប្រាស់ម៉ាក ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ មានសិទ្ធិប្តឹងទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ដើម្បីហាមឃាត់អ្នកនាំចូលដទៃទៀតក្រៅពីម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ដែលនាំចូលទំនិញក្រោមសិទ្ធិផ្តាច់មុខ និងអាចចាត់វិធានការតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ខ. ចំពោះការបន្តសុពលភាពនៃលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ៖

ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ មានសិទ្ធិប្តឹងទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ដើម្បីហាមឃាត់អ្នកនាំចូលដទៃទៀតក្រៅពីម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ដែលនាំចូលទំនិញក្រោមសិទ្ធិផ្តាច់មុខ និងអាចចាត់វិធានការតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន គិតចាប់ពីកាលបរិច្ឆេទសុពលភាពដែលបានកំណត់នៅក្នុងលិខិតបន្តសុពលភាពនៃការបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតបន្តសុពលភាពនៃការកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាករបស់ក្រសួងពាណិជ្ជកម្ម។

## ប្រការ១២.- ការបាត់បង់សុពលភាព

សុពលភាពនៃលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាកឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវបាត់បង់ជាស្វ័យប្រវត្តិ ប្រសិនបើ ៖

ក. ការប្រគល់សិទ្ធិផ្តាច់មុខ ឬការប្រគល់សិទ្ធិផ្តាច់មុខបន្ត ត្រូវបានដកហូតវិញពីអ្នកប្រគល់សិទ្ធិ ឬ

ខ. ម៉ាកត្រូវបានលុបចេញពីបញ្ជីម៉ាកនៅក្រសួងពាណិជ្ជកម្ម ឬ

គ. ម៉ាកត្រូវបានប្តូរម្ចាស់កម្មសិទ្ធិ ឬ

ឃ. ការអនុញ្ញាតឱ្យនាំចូលទំនិញជាប់កម្រិតកំណត់ ឬការចុះបញ្ជីផលិតផលជាប់កម្រិតកំណត់ ត្រូវបានដកហូតវិញ ដោយក្រសួង ស្ថាប័ន ឬរាជរដ្ឋាភិបាល។

## ប្រការ១៣.- ការធ្វើមោឃភាព

ការធ្វើមោឃភាពនៃលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវមានលក្ខខណ្ឌដូចខាងក្រោម ៖

១. បុគ្គលពាក់ព័ន្ធអាចស្នើសុំមកក្រសួងពាណិជ្ជកម្ម ឱ្យធ្វើមោឃភាពលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកបាន។

២. ក្រសួងពាណិជ្ជកម្ម មានសិទ្ធិធ្វើមោឃភាពលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ក្នុងករណីដូចខាងក្រោម ៖

ក. លិខិតបញ្ជាក់ ឬលិខិតកត់ត្រាខាងលើ មិនបានបំពេញលក្ខខណ្ឌតម្រូវនៃប្រការ៩ ប្រការ១០ ប្រការ១១ ប្រការ១២ ឬច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬ

ខ. ការផ្ដល់លិខិតប្រគល់សិទ្ធិផ្ដាច់មុខ និងឯកសារភ្ជាប់មានលក្ខណៈមិនស្របច្បាប់។

គ. ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ អនុវត្តផ្ទុយនឹងសារាចរណែនាំលេខ ០៧ សរណន ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការទទួលស្គាល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក របស់រាជរដ្ឋាភិបាល ឬ

ឃ. មានការស្នើសុំពីម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកប្រគល់សិទ្ធិ និង/ឬពីអ្នកទទួលសិទ្ធិ ដោយភ្ជាប់មកជាមួយនូវឯកសារគាំទ្រ និងភស្តុតាងគ្រប់គ្រាន់។

៣. ការស្នើសុំធ្វើមោឃភាពលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវបង់កម្រៃតាមប្រកាសអន្តរក្រសួងស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ហើយកម្រៃដែលបានបង់រួច មិនអាចដកយកមកវិញ ឬផ្ទេរបានឡើយ។

៤. ការធ្វើមោឃភាពនៃលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាកមានប្រសិទ្ធភាពអនុវត្តចាប់ពីកាលបរិច្ឆេទនៃការចេញសេចក្ដីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ១៤_ ការបន្តសុពលភាព**

១. ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ដែលមានបំណងបន្តសុពលភាពនៃលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវដាក់ពាក្យស្នើសុំឱ្យបានមុន ៣០(សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទផុតសុពលភាពនៃលិខិតបញ្ជាក់សិទ្ធិផ្ដាច់ មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ហើយត្រូវបំពេញតាមនីតិវិធី និងលក្ខខណ្ឌ ដូចខាងក្រោម ៖

ក. អ្នកដាក់ពាក្យស្នើសុំ ត្រូវមានកាតព្វកិច្ចបង់កម្រៃសេវាសាធារណៈជូនរដ្ឋ ដូចមានចែងនៅក្នុងកម្រងសេវាសាធារណៈ ក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

ខ. ផ្ដល់លិខិតប្រគល់សិទ្ធិផ្ដាច់មុខនៅមានសុពលភាពច្បាប់ដើម ឬថតចម្លងដែលមានបញ្ជាក់ភាពត្រឹមត្រូវ ឬលិខិតបញ្ជាក់ការអនុញ្ញាតឱ្យប្រគល់សិទ្ធិបន្ត និងលិខិតប្រគល់សិទ្ធិផ្ដាច់មុខបន្តនៅមានសុពលភាពច្បាប់ដើម ឬថតចម្លង ដែលមានបញ្ជាក់ភាពត្រឹមត្រូវ

គ. ផ្ដល់វិញ្ញាបនបត្រចុះបញ្ជីម៉ាកថតចម្លងនៅមានសុពលភាព

ឃ. ត្រូវបំពេញលក្ខខណ្ឌ និងឯកសារតម្រូវ ដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ។

២. ការបន្តសុពលភាពលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក និងការបន្តសុពលភាពលិខិតកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក មានរយៈពេល ២(ពីរ) ឆ្នាំ។ ក្នុងករណីដែលសុពលភាពរបស់លិខិតប្រគល់សិទ្ធិផ្ដាច់មុខ ឬសុពលភាពនៃវិញ្ញាបនបត្រចុះបញ្ជីម៉ាកមានរយៈពេលតិចជាង ២(ពីរ) ឆ្នាំ រយៈពេលសម្រាប់ការបន្តសុពលភាពនៃលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក និងរយៈពេលសម្រាប់ការបន្តសុពលភាព លិខិតកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវយកតាមសុពលភាពណាដែលមានរយៈពេលតិចជាង ដែលមាននៅក្នុងលិខិតប្រគល់សិទ្ធិផ្ដាច់មុខ ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក។

៣. លិខិតបន្តសុពលភាពការបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក និងលិខិតបន្តសុពលភាពការកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក មានប្រសិទ្ធភាពអនុវត្តចាប់ពីកាលបរិច្ឆេទដែលបានកំណត់នៅក្នុងលិខិតបន្តសុពលភាព

ការបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក និងលិខិតបន្តសុពលភាពការកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក របស់ក្រសួងពាណិជ្ជកម្ម។

៤. បន្ទាប់ពីក្រសួងពាណិជ្ជកម្ម បានចេញលិខិតបន្តសុពលភាពបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក និងលិខិតបន្តសុពលភាពការកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ត្រូវផ្សព្វផ្សាយជាបន្ទាន់ ដូចមានចែងក្នុងប្រការ១១(២)(ក) និង (ខ) នៃប្រកាសនេះ។

៥. ក្នុងករណីម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ដាក់ពាក្យស្នើសុំបន្តសុពលភាពលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតបន្តសុពលភាពការកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ក្រោយកាលបរិច្ឆេទកំណត់ដូចមានចែងក្នុងប្រការ១៤(១) នៃប្រកាសនេះ ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ មិនអាចដាក់ពាក្យស្នើសុំបន្តសុពលភាពបានទេ ប៉ុន្តែអាចដាក់ពាក្យស្នើសុំការបញ្ជាក់ថ្មីនៃលិខិតប្រគល់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក និងការកត់ត្រាថ្មីនៃលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាកបាន ហើយលិខិតរបស់ក្រសួងពាណិជ្ជកម្មត្រូវចាត់ទុកថាជាលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខថ្មីពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខថ្មីក្នុងការប្រើប្រាស់ម៉ាក ហើយមានប្រសិទ្ធភាពអនុវត្តដូចមានចែងក្នុងប្រការ១១(៣)(ក) ដែលម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ មានសិទ្ធិប្ដឹងទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ក្នុងរយៈពេល ៩០(កៅសិប) ថ្ងៃបន្ទាប់។ រយៈពេលនៃការអនុវត្តសិទ្ធិមានកំណត់ក្នុងលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខថ្មីពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខថ្មីក្នុងការប្រើប្រាស់ម៉ាកផងដែរ។

## ប្រការ១៥._ រយៈពេលនៃការប្ដឹងតវ៉ា

១. បុគ្គលពាក់ព័ន្ធមានសិទ្ធិប្ដឹងតវ៉ាទៅក្រុមប្រឹក្សាដោះស្រាយបណ្ដឹងតវ៉ានៃក្រសួងពាណិជ្ជកម្ម ឬតុលាការ ក្នុងរយៈពេល ៩០(កៅសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្ដីសម្រេចពាក់ព័ន្ធនឹងលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក ឬការកត់ត្រាលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ដោយក្រសួងពាណិជ្ជកម្ម។

២. សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្ដឹងតវ៉ានៃក្រសួងពាណិជ្ជកម្ម ជាកម្មវត្ថុនៃការប្ដឹងតវ៉ាទៅតុលាការក្នុងរយៈពេល ៩០(កៅសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្ដឹងតវ៉ានៃក្រសួងពាណិជ្ជកម្ម។

## ប្រការ១៦._ ការរំលោភបំពានសិទ្ធិ និងនីតិវិធីដោះស្រាយវិវាទ

ការរំលោភបំពានសិទ្ធិនាំចូលទំនិញក្រោមសិទ្ធិផ្ដាច់មុខត្រូវដោះស្រាយ ដូចខាងក្រោម ៖

១. ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ អាចចេញលិខិតព្រមានដល់អ្នកនាំចូលស្របគ្នាដទៃទៀតដែលនាំចូលទំនិញក្រោមសិទ្ធិផ្ដាច់មុខ ឱ្យបញ្ឈប់ការនាំចូលដែលរំលោភបំពានទៅលើសិទ្ធិស្របច្បាប់របស់ខ្លួន។

២. តាមការស្នើសុំពីម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ក្រសួងពាណិជ្ជកម្មអាចចេញលិខិតព្រមានដល់អ្នកនាំចូលស្របគ្នាដទៃទៀត ដែលនាំចូលទំនិញក្រោមសិទ្ធិផ្ដាច់មុខ ឱ្យបញ្ឈប់ការនាំចូលទំនិញដែលរំលោភបំពានទៅលើសិទ្ធិស្របច្បាប់របស់ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ។

៣. ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ និងអ្នកនាំចូលដទៃទៀត អាចធ្វើការសម្របសម្រួលគ្នា ដូចខាងក្រោម៖

- អនុញ្ញាតឱ្យអ្នកនាំចូលទំនិញក្រោមសិទ្ធិផ្ដាច់មុខ បន្តលក់ទំនិញ ដែលបាននាំចូលរួចមកហើយ ឱ្យអស់ពីក្នុងស្តុក ប៉ុន្តែត្រូវមានការទូទាត់សំណងនៃការខូចខាតក្នុងតម្លៃសមស្រប ជូនម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ឬ
- ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ទទួលទិញទំនិញខាងលើតាមថ្លៃសមស្រប។

៤. ក្នុងករណីដែលភាគីវិវាទគ្មានការឯកភាពគ្នាតាមជម្រើសណាមួយនៃចំណុចខាងលើ ទំនិញដែលនាំចូលនោះត្រូវបញ្ជូនត្រឡប់ទៅប្រទេសដើមវិញ។

៥. ភាគីវិវាទត្រូវធ្វើកំណត់ហេតុអំពីលទ្ធផលនៃការសម្របសម្រួល ដោយចុះហត្ថលេខា ឬផ្តិតមេដៃ ដែលមានការបញ្ជាក់ពីមេធាវី ឬអាជ្ញាធរមានសមត្ថកិច្ច ហើយបញ្ជូនកំណត់ហេតុនេះមួយច្បាប់មកក្រសួងពាណិជ្ជកម្ម។

៦. កំណត់ហេតុស្តីពីលទ្ធផលសម្របសម្រួលអាចប្រើប្រាស់ជាឯកសារគាំទ្រ ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៧. ភាគីទាំងពីរ អាចជ្រើសរើសយកយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ឬដាក់ពាក្យបណ្តឹងទៅតុលាការ។

**ប្រការ១៧.- និរាករណ៍**

ប្រកាសលេខ ១៨៦ ព.ណ.កសប.ប្រក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ស្តីពីនីតិវិធីសម្រាប់ការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ របស់ក្រសួងពាណិជ្ជកម្ម ត្រូវទុកជានិរាករណ៍។

**ប្រការ១៨.- អវសានប្បញ្ញត្តិ**

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន និងគ្រប់ប្រធានអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៨
- ឯកសារ កាលប្បវត្តិ